ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខៈ ៣៨៣ រថ.ទស.ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់ ការពន្យារបន្ត និងការផ្ទេរសិទ្ធិ អាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម សម្រាប់គោលបំណងអាជីវកម្ម ថ្មសំណង់ ថ្មអារ ឡាតេរីតអារ ថ្មម៉ាប ថ្មភក់ និងថ្មកែវ ឬសមាសធាតុធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

## សម្រេច

### ប្រការ ១.-

ប្រកាសនេះមានគោលបំណង៖

១- កំណត់នូវនីតិវិធី បែបបទ និងលក្ខខណ្ឌចាំបាច់នានាក្នុងការផ្តល់ ការពន្យារបន្ត ការផ្ទេរសិទ្ធិអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម សម្រាប់គោលបំណងជម្រុញការ



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

គ្រប់គ្រង ការធ្វើអាជីវកម្មថ្មសំណង់ ថ្មអារ ឡាតេរីតអារ ថ្មម៉ាប ថ្មភក់ ថ្មកែវ ឬសមាសធាតុធនធានរ៉ែផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងនិងការអាជីវកម្មធនធានរ៉ែ។

២- ជម្រុញតម្លាភាព ការទទួលខុសត្រូវ និងភាពឆ្លើយតបនៅក្នុងដំណើរការពិនិត្យវាយតម្លៃពាក្យស្នើសុំអាជ្ញាបណ្ណនិងគម្រោងអាជីវកម្មថ្មសំណង់ ថ្មអារ ឡាតេរីតអារ ថ្មម៉ាប ថ្មភក់ ថ្មកែវ ឬ សមាសធាតុធនធានរ៉ែផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាដោយរូបវន្តបុគ្គល ឬនីតិបុគ្គល។

**ប្រការ ២.-**

ប្រកាសនេះមានវិសាលភាពគ្របដណ្តប់លើរាល់សកម្មភាពធ្វើអាជីវកម្ម និងរាល់សកម្មភាពទាំងឡាយដែលទាក់ទងទៅនឹងប្រតិបត្តិការធនធានរ៉ែសំណង់ មានជាអាទិ៍ ថ្មសំណង់ ថ្មអារ ឡាតេរីតអារ ថ្មម៉ាប ថ្មភក់ ថ្មកែវ ឬសមាសធាតុធនធានរ៉ែផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានបំណងធ្វើសកម្មភាពអាជីវកម្មដូចមានកំណត់ក្នុងប្រការ២ខាងលើ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មស្របតាមនីតិវិធី បែបបទ និងលក្ខខណ្ឌដែលកំណត់ក្នុងប្រកាសនេះ។

**ប្រការ ៤.-**

សំណុំលិខិតស្នើសុំអាជ្ញាបណ្ណ ស្របតាមប្រការ៣ខាងលើ ត្រូវស្នើសុំមករដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល តាមរយៈមន្ទីររ៉ែនិងថាមពល រាជធានី ខេត្ត ដែលគម្រោងអាជីវកម្មមានទីតាំងស្ថិតនៅ។

សំណុំលិខិតស្នើសុំត្រូវបំពេញត្រឹមត្រូវ និងគ្រប់គ្រាន់តាមបែបបទបច្ចេកទេស និងស្របតាមការកំណត់ក្នុងប្រការ៥ ខាងក្រោម។

ប្រធានមន្ទីររ៉ែនិងថាមពល រាជធានី ខេត្ត មានភារកិច្ចចុះបញ្ជីការទទួលពាក្យ ផ្តល់មតិតាមការចាំបាច់ និងធ្វើដីកាបញ្ជូនសំណុំលិខិតទាំងអស់មកអគ្គនាយកដ្ឋានធនធានរ៉ែនៃក្រសួងរ៉ែនិងថាមពល ក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពីថ្ងៃទទួលពាក្យស្នើសុំគ្រប់គ្រាន់ស្របតាមប្រការ៥ នៃប្រកាសនេះ។

**ប្រការ ៥.-**

សំណុំលិខិតស្នើសុំអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម សម្រាប់គោលបំណងនៃប្រកាសនេះ ត្រូវមានភ្ជាប់ជាមួយនូវឯកសារខាងក្រោម៖

(ក) ពាក្យសុំអាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម តាមគំរូពាក្យដែលកំណត់ដោយក្រសួងរ៉ែនិងថាមពល............................................................ ចំនួន ១ច្បាប់

(ខ) ប្រវត្តិរូបសង្ខេប និងច្បាប់ចម្លងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (ដោយមានការបញ្ជាក់ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ........................................... ចំនួន ១ច្បាប់

(គ) ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ដោយមានការបញ្ជាក់ចម្លងត្រឹមត្រូវតាមច្បាប់ដើម) និងច្បាប់ចម្លងលក្ខន្តិកៈក្រុមហ៊ុន..........ចំនួន ១ច្បាប់

(ឃ) របាយការណ៍សិក្សាវាយតម្លៃបឋម អំពីលក្ខណៈភូគព្ភសាស្ត្រនិងសក្តានុពលធនធានរ៉ែ ......................................................................................................ចំនួន១ច្បាប់

(ង) គម្រោងផែនការអាជីវកម្ម និងផលិតកម្ម ដោយរួមមានវិធានការចូលរួមលើកកំពស់ផលប្រយោជន៍សេដ្ឋកិច្ចសង្គមនៅមូលដ្ឋាន..............ចំនួន ១ច្បាប់

(ច) របាយការណ៍វាយតម្លៃបឋមនៃផលប៉ះពាល់បរិស្ថាននិងសង្គម និងផែនការការពារបរិស្ថាន និងកិច្ចព្រមព្រៀងសហគមន៍ ក្នុងករណីមានផលប៉ះពាល់ជាមួយសហគមន៍មូលដ្ឋាន..........................................................ចំនួន ១ច្បាប់

(ឆ) ផែនការនិងគម្រោងប៉ាន់ស្មានថវិកាសម្រាប់ស្តារការដ្ឋានឡើងវិញ...................... ......................................................................................................ចំនួន ១ច្បាប់

(ជ) គម្រោងស្នើផែនការហិរញ្ញប្បទាន......................................................ចំនួន ១ច្បាប់

(ឈ) លិខិតអនុញ្ញាតផ្សេងៗចេញដោយស្ថាប័នមានសមត្ថកិច្ចស្របតាមច្បាប់ជាធរមាន ...................................................................................................... ចំនួន ១ច្បាប់

(ញ) វិក្កយបត្របញ្ជាក់ការទូទាត់កម្រៃពាក្យស្នើសុំអាជ្ញាបណ្ណ.................ចំនួន ១ច្បាប់

**ប្រការ ៦.-**

អាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មអាចផ្តល់ឲ្យចំពោះតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសមត្ថភាពបច្ចេកទេស ហិរញ្ញវត្ថុ និងបានចុះបញ្ជីពាណិជ្ជកម្មត្រឹមត្រូវ។

**ប្រការ ៧.-**

ការពិនិត្យវាយតម្លៃនិងផ្តល់អាជ្ញាបណ្ណស្របតាមប្រកាសនេះ ត្រូវអនុវត្តដោយផ្អែកលើសកម្មភាពអាជីវកម្មនិងប្រតិបត្តិការពាក់ព័ន្ធដែលផ្តល់លទ្ធភាពសេដ្ឋកិច្ចសង្គមល្អប្រសើរ និង សមស្របតាមគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់រាជរដ្ឋាភិបាល។

**ប្រការ ៨.-**

ការឆ្លើយតបអំពីការសម្រេចផ្តល់ ឬបដិសេធការផ្តល់អាជ្ញាបណ្ណស្របតាមប្រកាសនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយក្រសួងរ៉ែនិងថាមពលក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពីថ្ងៃបានទទួលសំណុំលិខិតស្នើសុំគ្រប់គ្រាន់តាមបែបបទបច្ចេកទេស។

**ប្រការ ៩.-**

សុពលភាពនៃអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មសម្រាប់គោលបំណងនៃប្រកាសនេះមានរយៈពេល ២(ពីរ)ឆ្នាំ និងអាចពន្យារបន្តបាន ៥(ប្រាំ)ដង ដែលម្តងៗមានសុពលភាពពុ ២(ពីរ)ឆ្នាំ។

សម្បទានិកដែលមានបំណងធ្វើអាជីវកម្មបន្តទៀត ត្រូវដាក់សំណុំលិខិតស្នើសុំពន្យារបន្តអាជ្ញាបណ្ណមកក្រសួងរ៉ែនិងថាមពល ដើម្បីពិនិត្យនិងសម្រេចដោយភ្ជាប់មកជាមួយនូវៈ

(ក) ពាក្យសុំពន្យារបន្តអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម......ចំនួន១ច្បាប់

(ខ) របាយការណ៍ស្តីពីបរិមាណផលិតកម្មរ៉ែសំណង់ដែលបានអនុវត្តក្នុងរយៈពេលសុពលភាពនៃអាជ្ញាបណ្ណមុន .............................................. ចំនួន ១ច្បាប់

(គ) របាយការណ៍ស្តីពីការការពារបរិស្ថាននៅក្រៅនិងក្នុងការដ្ឋានរ៉ែ និងការអនុវត្តកម្មវិធីស្តារឡើងវិញ ........................................................ចំនួន ១ច្បាប់

(ឃ) របាយការណ៍ស្តីពីការបង់ជូនរដ្ឋនូវសួយសារ ឈ្នួលដីប្រចាំឆ្នាំ និងពន្ធអាករពាក់ព័ន្ធដោយភ្ជាប់មកជាមួយនូវច្បាប់ចម្លងសក្ខីបត្រ.........................ចំនួន ១ច្បាប់

(ង) ផែនការអាជីវកម្មរ៉ែសំណង់ ផែនការស្តារការដ្ឋានរ៉ែឡើងវិញ.......ចំនួន ១ច្បាប់

**ប្រការ ១០.-**

នៅពេលផុតសុពលភាពនៃអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម ប្រសិនបើសម្បទានិកណាមួយមិនបានដាក់ពាក្យសុំពន្យារបន្តអាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មដូចបានកំណត់ក្នុងប្រការ៩នៃប្រកាសនេះ ក្រសួងរ៉ែនិងថាមពលនឹងដកតំបន់សម្បទាននោះមកវិញទាំងស្រុង។ ក្នុងករណីនេះ សម្បទានិកត្រូវទទួលខុសត្រូវក្នុងការជំរះបំណុលពាក់ព័ន្ធទាំងអស់ដែលរួមមានជាអាទិ៍ សួយសារ ឈ្នួលដីប្រចាំឆ្នាំ ពន្ធលើប្រាក់ចំណេញនិងពន្ធអាករពាក់ព័ន្ធផ្សេងទៀត មូលនិធិសង្គម មូលនិធីគ្រប់គ្រងនិងបណ្តុះបណ្តាល និងមូលនិធិសម្រាប់ការស្តារឡើងវិញដែលនៅសល់មុនពេលផុតសុពលភាពនៃអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម ព្រមទាំងត្រូវទទួលខុសត្រូវក្នុងការស្តារការដ្ឋានរ៉ែសំណង់ទាំងឡាយដែលស្ថិតនៅក្រោមអាជ្ញាបណ្ណ អណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មនោះ។

**ប្រការ ១១.-**

សម្បទានិកដែលមានអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម ហើយដែលមានបំណងផ្ទេរសិទ្ធិទាំងស្រុង ឬផ្នែកណាមួយនៃអាជ្ញាបណ្ណនោះ ទៅឲ្យបុគ្គលណាមួយ ត្រូវដាក់ពាក្យសុំផ្ទេរសិទ្ធិមកក្រសួងរ៉ែនិងថាមពល ដើម្បីពិនិត្យនិងសម្រេចដោយភ្ជាប់មកជាមួយនូវៈ

(ក) លិខិតស្នើសុំផ្ទេរសិទ្ធិនៃអាជ្ញាបណ្ណធនធានរ៉ែពីភាគីផ្ទេរសិទ្ធិ ដោយមានការបញ្ជាក់មូលហេតុច្បាស់លាស់ .............................................. ចំនួន ១ច្បាប់

(ខ) លិខិតស្នើសុំទទួលសិទ្ធិនិងការទទួលខុសត្រូវទាំងស្រុងពីភាគីទទួលសិទ្ធិដោយមានការបញ្ជាក់មូលហេតុច្បាស់លាស់ .......................... ចំនួន ១ច្បាប់

(គ) របាយការណ៍ស្តីពីការជំរះបំណុលសួយសារ ឈ្នួលដីប្រចាំឆ្នាំ និងពន្ធអាករពាក់ព័ន្ធផ្សេងទៀតដោយភ្ជាប់មកជាមួយនូវច្បាប់ចម្លងសក្ខីបត្រ ...........ចំនួន ១ច្បាប់

(ឃ) ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ដោយមានការបញ្ជាក់ចម្លងត្រឹមត្រូវតាមច្បាប់ដើម) និងច្បាប់ចម្លងលក្ខន្តិកៈក្រុមហ៊ុនរបស់ភាគីទទួលសិទ្ធិ ......... ......................................................................................... ចំនួន ១ច្បាប់

(ង) របាយការណ៍ស្តីពីសមត្ថភាពហិរញ្ញវត្ថុរបស់ភាគីទទួលសិទ្ធិ....... ចំនួន ១ច្បាប់

(ច) ផែនការគ្រប់គ្រង ផែនការស្តារឡើងវិញរបស់ភាគីទទួលសិទ្ធិ .... ចំនួន ១ច្បាប់

**ប្រការ ១២**.-

ក្នុងករណីអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មត្រូវបានព្យួរទុក ឬដកហូត សម្បទានិកត្រូវទទួលខុសត្រូវក្នុងការជំរះបំណុលពាក់ព័ន្ធទាំងអស់ដែលរួមមានជាអាទិ៍ សួយសារ ឈ្នួលដីប្រចាំឆ្នាំ ពន្ធលើប្រាក់ចំណេញនិងពន្ធអាករពាក់ព័ន្ធផ្សេងទៀត មូលនិធិសង្គម មូលនិធិគ្រប់គ្រងនិងបណ្តុះបណ្តាល និងមូលនិធិសម្រាប់ការស្តារឡើងវិញដែលនៅសល់មុនពេលព្យួរទុក ឬដកហូតអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម ព្រមទាំងត្រូវទទួលខុសត្រូវក្នុងការស្តារការដ្ឋានរ៉ែសំណល់ទាំងឡាយដែលស្ថិតនៅក្រោមអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មនោះ។

**ប្រការ ១៣**.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៤** .-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

ស៊ុយ សែម

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត
- ដូចប្រការ១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ